# អាស៊ីទទួលយកចំណុចដៅថ្មីនៃវឌ្ឍនភាព
## ១០ ឆ្នាំ ដើម្បីធ្វើអោយការងារថ្លៃថ្នូរក្លាយជាការពិត

*ដោយលោក* ***Ng Gek Boo*** *នាយកប្រចាំតំបន់នៃអង្គការពលកម្មអន្តរជាតិ សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក*

ប៊ូសាន សាធារណៈរដ្ឋកូរ៉េ – កិច្ចប្រជុំប្រចាំតំបន់អាស៊ីរបស់អង្គការពលកម្មអន្តរជាតិ (ILO) លើកទី ១៤ បានបញ្ចប់នៅទីនេះ ជាមួយនឹងការប្តេជ្ញាចិត្ត ដើម្បីបង្កើត "ទស្សវត្សនៃការងារថ្លៃថ្នូរនៅអាស៊ី" មួយ សំដៅជំរុញវឌ្ឍនភាពឆ្ពោះទៅសំរេចអោយបាននូវការងារថ្លៃថ្នូរ នៅក្នុងតំបន់ដែលពោរពេញទៅដោយភាពចំរុះមួយនេះ ។

នេះគឺជាការបោះជំហានទៅមុខយ៉ាងមានសារៈសំខាន់មួយ សំរាប់កម្មករនិយោជិតរាល់រូបនៅអាស៊ី ប៉ាស៊ីហ្វិក និង រដ្ឋអារ៉ាប់ ដែលជាសមាជិករបស់អង្គការពលកម្មអន្តរជាតិ ។ ការសំរេចបាននូវការងារថ្លៃថ្នូរអាចជួយមនុស្សគ្រប់រូប និង កូនៗរបស់ពួកគេ មិនថាស្រីឬប្រុស ក្មេងឬចាស់ មានជំនាញឬមានការអប់រំតិចតួច អោយទទួលបានចំណែកប្រយោជន៏ចេញពីកំណើនសេដ្ឋកិច្ចយ៉ាងសំបើមរបស់តំបន់នេះ កាន់តែស្មើភាពគ្នា ។ ហើយការណ៍នេះមិនត្រឹមតែល្អប្រសើរសំរាប់ពួកគេ និង សង្គមរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងល្អប្រសើរសំរាប់យើងទាំងអស់គ្នាក្នុងរយៈពេលវែងថែមទៀតផង ព្រោះការបែងចែកប្រយោជន៏នៃសកលភាវូបនីយកម្មមិនស្មើភាពគ្នា ជំរុញបង្កើតអោយមានពិភពលោកអស្ថិរភាពមួយ ។

នៅក្នុងរយៈពេលខ្លីតែពីរបីឆ្នាំប៉ុណ្ណោះ ការងារថ្លៃថ្នូរបានផ្លាស់ប្តូរទីតាំងពីចក្ខុវិស័យដើមរបស់ខ្លួននៅឯអង្គការពលកម្មអន្តរជាតិ ទៅជាការពិតនៅក្នុងរបៀបវារៈ និង ការជជែកវែកញែក របស់គោលនយោបាយជាតិ ។ ឥលូវនេះ មហាសន្និបាតអង្គការសហប្រជាតិជាតិក្នុងទីក្រុងញូយ៉ក និង ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (ECOSOC) របស់អង្គការកំពូលមួយនេះ បានពាំនាំយកគំនិតនៃការងារថ្លៃថ្នូរទៅកាន់កំរិតនយោបាយខ្ពស់បំផុត ។ នាពេលបច្ចុប្បន្ននេះ សង្គមនៅគ្រប់កំរិតទាំងអស់ទទួលស្គាល់ថា ការងារថ្លៃថ្នូរគឺជាគំនិតមួយ ដែលដល់ពេលត្រូវលេចរូបរាងឡើង ។

យ៉ាងណាក៏ដោយ មនុស្សជាច្រើនអាចសាកសួរថា តើគេអាចសំរេចបាននូវទសវត្សនៃការងារថ្លៃថ្នូរបែបនេះ

តាមរបៀបណា។ នៅក្នុងករណីនេះ សេចក្តីលំអិតត្រូវបានរៀបចំរួចរាល់អស់ហើយ ជាមួយនឹងកំណើនបញ្ជីកម្មវិធីការងារថ្លៃថ្នូរថ្នាក់ជាតិរបស់ប្រទេស ដែលរៀបចំឡើងទៅតាមអាទិភាពរបស់ប្រទេសនីមួយៗ និង អនុវត្តដោយប្រទេសទាំងនោះ ជាមួយនឹងជំនួយពីអង្គការពលកម្មអន្តរជាតិ ប្រសិនបើមានការស្នើរសុំ។

ជាពិសេស សេចក្តីលំអិតទាំងនេះនឹងផ្តោតលើ:

- លើកកំពស់អោយមានកំណើនផលិតភាពប្រកបដោយចីរភាព សេដ្ឋកិច្ចពោរពេញទៅដោយភាពប្រកួតប្រជែង និង ការបង្កើតការងារ
- ជំរុញអោយមានការផ្តល់សច្ចាប័នលើបទដ្ឋានការងារសំខាន់ៗ
- លើកកំពស់ការទទួលបានសេវាអប់រំសំរាប់ទាំងអស់គ្នា ដើម្បីធានាអោយមានជំនាញសមប្រកប សំដៅធ្វើអោយកាន់ប្រសើរនូវលទ្ធភាពអាចរកការងារធ្វើបានជាបន្ត
- លើកកំពស់អោយមានឱកាសការងារថ្លៃថ្នូរ និង សហគ្រិនភាពសំរាប់យុវជននិងយុវនារី ជាពិសេស តាមរយៈការសំរបសំរួលអន្តរកាលពីការអប់រំទៅកាន់ការធ្វើការងារ និង ការចែករំលែកការអនុវត្តល្អៗ
- លុបបំបាត់ទំរង់អាក្រក់បំផុតនៃពលកម្មកុមារ
- បង្កើនកិច្ចសន្ទនា និង ជំរុញអោយការគ្រប់គ្រងទេសន្តប្រវេសន៍ការងារកាន់តែមានភាពប្រសើរ ដើម្បីអោយទាំងប្រទេសបញ្ជូន និង ប្រទេសទទួលអ្នកធ្វើការងារក្នុងនាមជាទេសន្តប្រវេសន៍ជនទទួលបានអត្ថប្រយោជន៍ដូចគ្នា និង ដើម្បីការពារអោយបានកាន់តែប្រសើរនូវសិទ្ធិ និង ការប្រតិបត្តិស្មើគ្នារបស់អ្នកធ្វើការងារក្នុងនាមជាទេសន្តប្រវេសន៍ជន
- លើកកំពស់អភិបាលកិច្ចទីផ្សារការងារប្រកបដោយប្រសិទ្ធិភាព តាមរយៈការអនុម័ត ការអនុវត្ត និង ការពិនិត្យឡើងវិញនូវច្បាប់ការងារ និង គោលនយោបាយសង្គមទាំងឡាយណាដែលផ្ទុយនឹងគោលដៅនៃការងារពេញលេញ និង ប្រកបដោយផលិតភាព ដែលរបៀបវារៈការងារថ្លៃថ្នូរព្យាយាមសំរេចអោយបាន
- បង្កើតយន្តការភាពជាដៃគូទ្វេភាគី និង កិច្ចសហប្រតិបត្តិការគ្រប់គ្រងការងារ ក៏ដូចជា ស្ថាប័ន និង បទបញ្ញត្តិដទៃទៀត ដូចជា ក្របខ័ណ្ឌសំរាប់កិច្ចសន្ទនាសង្គម ដែលជាធាតុយ៉ាងសំខាន់ ដើម្បីអោយការ

បំពេញមុខងាររបស់ទីផ្សារការងារប្រកបដោយប្រសិទ្ធិភាព និង ភាពយុត្តិធម៌

- ពង្រីកបន្ថែមនូវប្រសិទ្ធិភាព និង វិសាលភាពនៃកិច្ចការពារសង្គមសំរាប់ទាំងអស់គ្នា ដែលរួមទាំងអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ

ឥលូវនេះ កិច្ចព្រមព្រៀងថ្មីនេះផ្តល់នូវការប្តេជ្ញាចិត្តផ្នែកនយោបាយ ដែលចាំបាច់ដើម្បីបង្កើតគោលនយោបាយនានា ដែលអាចលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសាមញ្ញ ។

ក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ អាស៊ីបាននាំមុខគេក្នុងពិភពលោកខាងកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ ។ ឥលូវនេះ ប្រទេសទាំងឡាយនៅក្នុងតំបន់នេះអាចបង្កើតជាឧទាហរណ៍មួយនៅក្នុងតំបន់មួយទៀត ដោយបង្ហាញថា គោលនយោបាយសង្គមអាចដើរទន្ទឹមគ្នាជាមួយនឹងដំណើរសេដ្ឋកិច្ច ក្នុងនាមជាមធ្យោបាយមួយ ដើម្បីផ្តល់អោយប្រជាពលរដ្ឋនូវជីវិតកាន់តែប្រសើរជាងមុន ។

តើគោលដៅនេះអាចសំរេចទៅបានដែរឬទេ? សេចក្តីថ្លែងរបស់តំណាងត្រីភាគី រួមមាន កម្មករនិយោជិត និយោជក និង រដ្ឋាភិបាល នៅសប្តាហ៍នេះគួសបញ្ជាក់យ៉ាងច្បាស់ ។

សេចក្តីថ្លែងបានរៀបរាប់ថា "យើងជឿជាក់ថា របៀបវារៈការងារថ្លៃថ្នូររបស់អង្គការពលកម្មអន្តរជាតិអាចចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តភាព ជួយក្នុងការសិក្សាវាយតំលៃលើកំណើនវិសមភាពសេដ្ឋកិច្ចទាំងនៅក្នុង និង រវាងប្រទេសនានានៅក្នុងតំបន់ និង ជាលទ្ធផល ចូលរួមចំណែកយ៉ាងសំខាន់ចំពោះការសំរេចអោយបាននូវគោលដៅអភិវឌ្ឍសហសវត្សថ្មី" ។

"យើងប្តេជ្ញាចិត្ត ដើម្បីធានាអោយបានច្បាស់ថា អាស៊ីនឹងបន្តភាពដឹកនាំខាងគោលនយោបាយសកលក្នុងការធ្វើអោយការងារថ្លៃថ្នូរសំរាប់ទាំងអស់គ្នា ក្លាយជាគោលដៅចំបងមួយនៃគ្រប់គោលនយោបាយជាតិនិងអន្តរជាតិនានាដែលពាក់ព័ន្ធ ក៏ដូចជានៃយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់យើងទាំងអស់គ្នា" ។

######